ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ០០២ ជនស/សាណន

# សេចក្តីណែនាំ
# ស្តីពី
# ការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំសំដៅពង្រឹងការអនុវត្តច្បាប់ស្តីពីសំណង់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ អគ្គនាយកដ្ឋានសំណង់ អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម៖

- ហាមដាច់ខាតការសាងសង់សំណង់ដែលគ្មានលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់។
- ហាមដាច់ខាតការអនុវត្តការងារសាងសង់ឬរុះរើ ដោយអ្នកសាងសង់ដែលគ្មានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- ហាមដាច់ខាតការដ្ឋានសំណង់ដែលដំណើរការសាងសង់ឬរុះរើដោយគ្មានវិស្វករប្រចាំការដ្ឋានជាអ្នកទទួលខុសត្រូវ។
- ហាមដាច់ខាតការស្នាក់នៅក្នុងអគារដែលកំពុងសាងសង់ ទោះបីជាលក្ខណៈបណ្តោះអាសន្នក៏ដោយ និងហាមដាច់ខាតអ្នកគ្មានភារកិច្ចចូលក្នុងការដ្ឋានសំណង់។
- ហាមការប្រើប្រាស់សំណង់គ្រប់ប្រភេទ ដោយគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ឬលិខិតបិទការដ្ឋានផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីពិនិត្យឃើញអំពើល្មើសនឹងបម្រាមខាងលើ អាជ្ញាធរមានសមត្ថកិច្ចត្រូវចេញលិខិតផ្អាកការសាងសង់ជាបន្ទាន់។ ក្នុងករណីការសាងសង់នៅតែបន្ត អាជ្ញាធរមានសមត្ថកិច្ចត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធីជាធរមាន។

ដើម្បីធានាសន្តិសុខនិងសុវត្ថិភាពនៃការដ្ឋានសំណង់ អាជ្ញាធរមានសមត្ថកិច្ច ត្រូវយកចិត្តទុកដាក់អនុវត្តគោលការណ៍និងវិធានការដូចខាងក្រោម÷

**១) លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ**


អាសយដ្ឋានៈ ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុន្នីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- គម្រោងប្លង់ស្ថាបត្យកម្មត្រូវសិក្សានិងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាស្ថាបត្យករ និងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- គម្រោងប្លង់រុះរើត្រូវសិក្សានិងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាវិស្វករនិងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- ការប្រើប្រាស់ ការប្រកបអាជីវកម្ម ការចាត់ចែង និងការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់គ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីគម្រោងប្លង់អនុញ្ញាត មិនត្រូវបានអនុញ្ញាតឡើយក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

**២) លិខិតអនុញ្ញាតបើកការដ្ឋានសំណង់**

- គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងគម្រោងប្លង់បច្ចេកទេសដទៃទៀតត្រូវសិក្សា និងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាវិស្វករនិងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងគម្រោងប្លង់បច្ចេកទេសដទៃទៀត ត្រូវមានការបញ្ជាក់អនុលោមភាពតាមបទដ្ឋានបច្ចេកទេសសំណង់ ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលទទួលស្គាល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវមានបញ្ជាក់អំពីអត្តសញ្ញាណរបស់អ្នកសាងសង់ វិស្វករប្រចាំការដ្ឋាន វិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន និងគម្រោងប្លង់រៀបចំការដ្ឋានសំណង់ដែលមានហត្ថលេខារបស់នាយកបច្ចេកទេស។

**៣) ការរៀបចំការដ្ឋាន**

- មន្ត្រីត្រួតពិនិត្យសំណង់ត្រូវចុះវាស់វែងនិងបោះបង្គោលព្រំកំណត់ទីតាំងដែលត្រូវសាងសង់ស្របតាមគម្រោងប្លង់ស្ថាបត្យកម្មដែលទទួលបានការយល់ព្រមតាមរយៈលិខិតអនុញ្ញាតសាងសង់។
- ការដ្ឋានសំណង់ត្រូវមានផ្ទាំងព័ត៌មានអំពីគម្រោងសាងសង់នៅពីមុខការដ្ឋានសំណង់ ជាអាទិ៍ ឈ្មោះគម្រោងសាងសង់ ឈ្មោះក្រុមហ៊ុនសាងសង់ ឈ្មោះមេក្រុមជាង ឈ្មោះម្ចាស់សំណង់ ឈ្មោះរបស់វិស្វករប្រចាំការដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ រូបភាពនៃគ្រោងទស្សន៍នៃគម្រោងសាងសង់ និងអាសយដ្ឋានទីតាំងសំណង់។
- ត្រូវយកចិត្តទុកដាក់ប្រតិបត្តិតាមវិធានសុវត្ថិភាពដូចមានកំណត់ក្នុងប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ និងសៀវភៅណែនាំអំពីសុវត្ថិភាពក្នុងការដ្ឋានសំណង់ (ឆ្នាំ២០១៨) របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ៤) ដំណើរការការដ្ឋានសំណង់

- មានតែក្រុមហ៊ុនសាងសង់ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទើបអាចទទួលម៉ៅការសាងសង់បាន។ ក្រុមហ៊ុនសាងសង់អាចចុះកិច្ចសន្យាបន្តដើម្បីប្រគល់ការងារមួយផ្នែកឬច្រើនទៅឱ្យក្រុមជាងសំណង់។ ក្នុងករណីនេះ ក្រុមជាងសំណង់ត្រូវអនុវត្តការងារក្រោមការទទួលខុសត្រូវរបស់ក្រុមហ៊ុននោះ។ វិស្វករប្រចាំការដ្ឋានត្រូវចាត់តាំងដោយក្រុមហ៊ុនសាងសង់។
- ក្រុមជាងដែលមានវិញ្ញាបនបត្រក្រុមជាងសំណង់ ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អាចទទួលម៉ៅការសាងសង់សំណង់ស្ថិតក្រោមសមត្ថកិច្ចអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។ ការងាររបស់ក្រុមជាងសំណង់ត្រូវស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់វិស្វករប្រចាំការដ្ឋានយ៉ាងតិច ០១ (មួយ) រូប ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងដែលបានចុះកិច្ចសន្យាជាមួយម្ចាស់សំណង់។
- គ្រប់ការដ្ឋានសំណង់ ត្រូវមានសៀវភៅតាមដានការងារសាងសង់ដើម្បីកត់ត្រាអំពីការងារសាងសង់ឬរុះរើជាប្រចាំ និងត្រូវដាក់ជូនមន្ត្រីត្រួតពិនិត្យសំណង់រាល់ពេលចុះត្រួតពិនិត្យ។
- អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់មន្ត្រីត្រួតពិនិត្យសំណង់ឱ្យចុះបំពេញការងារត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ជាប្រចាំ។ មន្ត្រីត្រួតពិនិត្យសំណង់មាន មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ។
- ក្រុមហ៊ុនសាងសង់ឬវិស្វករប្រចាំការដ្ឋាន ត្រូវជូនដំណឹងមកមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះពិនិត្យលើការងារសាងសង់តាមដំណាក់កាលដូចខាងក្រោម÷
    - ក្នុងពេលកំណត់ទីតាំងសាងសង់
    - ក្នុងពេលអនុវត្តការងារគ្រឹះ
    - ក្នុងពេលអនុវត្តការងារសសរជាន់ផ្ទាល់ដី
    - ក្នុងពេលអនុវត្តការងារគ្រឿងផ្គុំបន្តបន្ទាប់ទៀត។
- នៅរាល់ពេលចុះត្រួតពិនិត្យការដ្ឋាន មន្ត្រីត្រួតពិនិត្យសំណង់ត្រូវចុះហត្ថលេខាលើសៀវភៅតាមដានការងារសាងសង់ និងធ្វើកំណត់ហេតុត្រួតពិនិត្យសំណង់ដោយមានហត្ថលេខារបស់មន្ត្រីត្រួតពិនិត្យសំណង់ និងវិស្វករប្រចាំការដ្ឋាន និងស្នាមមេដៃរបស់ម្ចាស់សំណង់ និងអ្នកពាក់ព័ន្ធ។
- ក្នុងករណីពិនិត្យឃើញថា ការងារសាងសង់ឬរុះរើមិនអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់ គម្រោងប្លង់ស្ថាបត្យកម្មដែលបានអនុញ្ញាតហើយ និងបទប្បញ្ញត្តិជាធរមានដទៃទៀត អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឱ្យរុះរើឬវិធានការចាំបាច់ផ្សេងទៀត។

- អគ្គនាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវចងក្រងនិងរក្សារាល់កំណត់ហេតុ របាយការណ៍ត្រួតពិនិត្យសំណង់ រូបថត និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការដ្ឋានសំណង់នីមួយៗ ទាំងជាឯកសាររឹងនិងទាំងជាឯកសារអេឡិចត្រូនិក សម្រាប់ប្រើប្រាស់ក្នុងករណីចាំបាច់។

**៥) ការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់**

- គម្រោងប្លង់គ្រឿងផ្គុំសំណង់និងការងារសាងសង់ ត្រូវមានការត្រួតពិនិត្យនិងបញ្ជាក់អនុលោមភាពតាមបទដ្ឋានបច្ចេកទេសសំណង់ ដែលអនុវត្តដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ ដែលជាក្រុមហ៊ុនសិក្សាគម្រោងប្លង់ឬក្រុមហ៊ុនសាងសង់ដែលកំណត់ដោយសេចក្ដីសម្រេចរបស់ក្រសួង។
- ការត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់គ្រឿងផ្គុំសំណង់ ត្រូវអនុវត្តដាច់ខាតលើគម្រោងប្លង់ផ្នែកគ្រឹះ ជើងតាង សសរ ធ្នឹម កម្រាលខណ្ឌ និងជញ្ជាំងទ្រទម្ងន់។ ការត្រួតពិនិត្យនិងបញ្ជាក់លើការងារសាងសង់ ត្រូវអនុវត្តដាច់ខាតនៅតាមដំណាក់កាលសំខាន់ៗនៃការងារគ្រឿងផ្គុំ ជាអាទិ៍ ផ្នែកគ្រឹះ សសរ ធ្នឹម កម្រាលខណ្ឌ និងជញ្ជាំងទ្រទម្ងន់។
- វិញ្ញាបនបត្រត្រួតពិនិត្យនិងបញ្ជាក់សំណង់ចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ គឺជាឯកសារដែលអាជ្ញាធរមានសមត្ថកិច្ចប្រើប្រាស់ក្នុងការសម្រេចផ្ដល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលមានតម្លៃសម្រាប់ការចូលប្រើប្រាស់ ការដាក់ជួល ការលក់ ឬប្រតិបត្តិការពាណិជ្ជកម្មផ្សេងទៀតពាក់ព័ន្ធនឹងសំណង់។
- ក្នុងករណីពិនិត្យឃើញការងារសាងសង់មិនអនុវត្តតាមបទដ្ឋានបច្ចេកទេសសំណង់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវជូនដំណឹងជាបន្ទាន់ទៅមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចាត់វិធានការសមស្រប។

ទទួលបានសេចក្ដីណែនាំនេះ អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ អគ្គនាយកដ្ឋានសំណង់ អគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហ ១ រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល ÷**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យ **សម្ដេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  **"ដើម្បីជូនជ្រាប"**
- ឯកសារ-កាលប្បវត្តិ